**ព្រះរាជាណាចក្រកម្ពុជា**

**ក្រុមប្រឹក្សាធម្មនុញ្ញ** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ :** ០៥/៩៩ កបធ.ច.សស.រ

# សេចក្តីសម្រេច
# ស្តីពីការកែសម្រួលលើបទបញ្ជាស្តីពីនីតិវិធី
# ដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

*******

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ១៩៩៨
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានធ្វើវិសោធនកម្ម នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៨
- បានឃើញបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញលេខ ២៤ កបធ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៨
- បានអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
- តាមសំណើសុំធ្វើវិសោធនកម្មប្រការ ១២ នៃបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញរបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ៦ រូប ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ១៩៩៩
- យោងកំណត់ហេតុប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ១៩៩៩

## <u>សម្រេច</u>

ប្រការតែមួយ : ត្រូវបានកែសម្រួលបទបទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ នូវចំណុចមួយចំនួនដូច

ខាងក្រោមៈ

- កែចំណងជើងពី " បទបញ្ជាស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ " ទៅជា " បទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ " វិញ។

- បញ្ចូលក្នុងមូលបទនូវឃ្លា " បានឃើញព្រះរាជក្រម នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាស ឱ្យប្រើច្បាប់បន្ថែមទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ " ។

- កែសម្រួលប្រការ ១២ ពី " ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបើកសវនាការជាសាធារណៈដើម្បី ពិនិត្យ និងសម្រេចក្នុងរយៈពេលដែលមានកំណត់ក្នុងច្បាប់ " ទៅជា " ក្រុមប្រឹក្សាធម្មនុញ្ញ អាចបើកសវនាការជាសាធារណៈស្របតាមច្បាប់ដែលមាន ដើម្បីពិនិត្យ និង សម្រេច ក្នុងរយៈពេលដែលមានកំណត់ក្នុងច្បាប់" ។

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ចាន់ សុក**